# យកចិត្តទុកដាក់ដល់អ្នកដែលបាត់

អែលឌើរ យ៉ូសែប ប៊ី. វ៉ឺតលីន
នៃក្រុមសាវក 12 នាក់

*ព្រះយេស៊ូវគឺជាគំរូដ៏ល្អបំផុតរបស់យើង ។ ទ្រង់ត្រូវបានហ៊ុំព័ទ្ធដោយប្រជុំជន ហើយបានមានបន្ទូលទៅកាន់មនុស្សរាប់ពាន់នាក់ ពីព្រោះតែទ្រង់តែងតែព្រួយបារម្ភដល់មនុស្សម្នាក់ៗ ។*

ខ្ញុំមានអំណរគុណសំរាប់ឱកាសនៅជាមួយអ្នកទាំងអស់គ្នាថ្ងៃនេះ នៅក្នុងមជ្ឈមណ្ឌលសន្និសីទដ៏អធិកអធមនេះ ។ ចំនួនដ៏ច្រើននៃក្រុមជំនុំនៅទីនេះ គឺកំពុងតែបានដឹងដោយរាបសារថា វាគ្រាន់តែមួយភាគតូច ក្នុងចំណោមមនុស្សរាប់លាននាក់ ដែលនឹងមើលឃើញ ស្តាប់ឮ និងអានពាក្យពេចន៍ក្នុងមហាសន្និសីទនេះ ។

ជាការពិតណាស់យើងនឹងនឹកប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ជាទីស្រឡាញ់របស់យើង ។ ទោះជាយ៉ាងណាក្តី យើងជាមនុស្សប្រសើរជាងមុន ពីព្រោះតែឥទ្ធិពលរបស់លោក ។ សាសនាចក្រកាន់តែរឹងមាំ ពីព្រោះតែការដឹកនាំរបស់លោក ។ ជាងនេះទៅទៀតពិភពលោកជាកន្លែងដែលកាន់តែប្រសើរ ពីព្រោះតែមានអ្នកដឹកនាំដូចប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ។

ខ្ញុំចង់និយាយបន្តិចអំពីគណៈប្រធានទីមួយថ្មីរបស់យើង ។ ខ្ញុំបានស្គាល់ប្រធានម៉នសុន យូរមកហើយ ។ លោកគឺជាបុរសខ្លាំងពូកែនៃអ៊ីស្រាអែល ដែលបានតែងតាំងពីមុនជីវិតនេះដើម្បីគ្រប់គ្រងសាសនាចក្រនេះ ។ លោកមានឈ្មោះល្បីដោយសាររឿងរ៉ាវគួរឱ្យចាប់អារម្មណ៍ និងប្រៀបប្រដូចរបស់លោក ប៉ុន្តែចំពោះយើងដែលស្គាល់លោកយល់ដឹងយ៉ាងច្បាស់ថា ជីវិតរបស់លោកគឺជាគំរូយ៉ាងធម្មតា និងសាមញ្ញ នៃការអនុវត្តនៃដំណើររឿងទាំងអស់នោះ ។ ខណៈពេលដែលមានការកោតសរសើរចំពោះលោក មនុស្សអស្ចារ្យនិងមានអំណាចនៃពិភពលោកនេះជាច្រើនបានស្គាល់ ហើយគោរពលោក ប្រហែលនេះគឺជាវិភាគទានយ៉ាងអស្ចារ្យដែលមនុស្សឋានៈតូចទាបខ្លះហៅលោកថា មិត្តសម្លាញ់ ។

ដួងចិត្តរបស់លោក ប្រធានម៉នសុន ជាមនុស្សចិត្តល្អ និងមេត្តាករុណា ។ ពាក្យសំដី និងឧទាហរណ៍ជ្រៅៗរបស់លោក គឺបង្ហាញពីកង្វល់ចំពោះមនុស្សគ្រប់រូប ។

ប្រធានអាវិង ជាបុរសឈ្លាសវៃ មានការអប់រំ និងជាបុរសដែលពោរពេញទៅដោយវិញ្ញាណ ។ លោកមិនត្រឹមតែមានឈ្មោះល្បី និងទទួលការគោរពនៅក្នុងសាសនាចក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានពីមនុស្សដែលមានជំនឿផ្សេងទៀតផងដែរ ។ លោកគឺជាប្រភេទមនុស្សដែលពេលលោកនិយាយ ធ្វើឱ្យមនុស្សគ្រប់រូបស្តាប់ ។ លោកបានបន្ថែមនូវភាពខ្ពង់ខ្ពស់ចំពោះឈ្មោះ *អាវិង* ។

ខ្ញុំបានស្គាល់ប្រធានអុជដូហ្វ ពេលខ្ញុំបំរើជាគណៈប្រធានតំបន់នៅអឺរ៉ុប ។ ខ្ញុំបានជួបលោកតែមួយភ្លែតតែប៉ុណ្ណោះ ខ្ញុំបានដឹងភ្លាមថាលោកជាមនុស្សដែលផ្នែកព្រលឹងវិញ្ញាណរបស់លោកជ្រាលជ្រៅអស្ចារ្យ និងមានសមត្ថភាពដ៏មហិមា ។ ខ្ញុំដឹងថាព្រះអម្ចាស់ខ្វល់ខ្វាយចំពោះលោក ។ ម្ភៃបីឆ្នាំកន្លងទៅហើយ ខ្ញុំមានកិត្តិយសក្នុងការពង្រីកនូវការហៅរបស់ព្រះអម្ចាស់ចំពោះលោកដើម្បីបំរើ ជាប្រធានស្តេកនៅហ្វ្រែហ្វហ្វើត ប្រទេសអាល្លឺម៉ង់ ។ ខណៈពេលដែលខ្ញុំគ្រប់គ្រងជាច្រើនឆ្នាំ ខ្ញុំបានកត់សំគាល់ឃើញថា អ្វីគ្រប់យ៉ាងដែលនៅក្រោមការដឹកនាំរបស់លោក គឺតែងតែមាន

ជោគជ័យ។ ព្រះអម្ចាស់គង់នៅជាមួយលោក។ ពេលខ្ញុំបានគិតពីប្រធានអុជដូហ្វ នោះមានពាក្យពីរម៉ាត់ចូលមកក្នុងគំនិតខ្ញុំគឺ: *alles wohl*--- ជាភាសាអាល្លឺម៉ង់ នោះមានន័យថា "ស្រួលទាំងអស់"។

## ***សិស្សពិតរបស់ព្រះយេស៊ូវគ្រីស្ទ តែងយកចិត្តទុកដាក់ដល់អ្នកដែលបាត់***

ព្រះយេស៊ូវគ្រីស្ទជាគំរូដ៏អស្ចារ្យជាងគេរបស់យើង។ ទ្រង់បានពទ្ធ័ជុំវិញដោយបណ្ដាជនជាច្រើន ហើយមានបន្ទូលទៅកាន់មនុស្សរាប់ពាន់នាក់ ហើយទ្រង់តែងយកចិត្តទុក្ខដាក់ដល់អ្នកដែលបាត់។ ទ្រង់មានបន្ទូលថា: "ត្បិតកូនមនុស្សបានមក ដើម្បីនឹងជួយសង្គ្រោះអ្នកណាដែលបាត់បង់"1 "ក្នុងពួកអ្នករាល់គ្នា បើអ្នកណាមានចៀមមួយរយ តែបាត់មួយ តើមិនទុកចៀមកៅសិបប្រាំបួនឱ្យនៅទីរហោស្ថាន ហើយទៅតាមរកចៀមមួយ ដែលបាត់ទាល់តែឃើញទេឬអី?" 2

សេចក្ដីណែនាំនេះអនុវត្តចំពោះជនទាំងឡាយដែលដើរតាមទ្រង់។ យើងត្រូវបានបញ្ជាឱ្យស្វែងរកអស់អ្នកដែលបាត់។ យើងជាអ្នកមើលថែបងប្អូនប្រុសរបស់យើង។ យើងមិនត្រូវព្រងើយកន្តើយនឹងថ្លៃដែលព្រះអង្គសង្គ្រោះយើងបានបង់ឱ្យនោះទេ។ យើងត្រូវយកចិត្តទុកដាក់ចំពោះអស់អ្នកដែលបាត់។

ថ្ងៃនេះខ្ញុំចង់និយាយចំពោះអស់អ្នកដែលបាត់---ដែលមួយចំនួនពីព្រោះតែពួកគេខុសពីយើង និងមួយចំនួនពីព្រោះតែពួកគេអស់កម្លាំង ហើយមួយចំនួនទៀតពីព្រោះតែពួកគេវង្វេង។

## ***មួយចំនួនពីព្រោះតែពួកគេខុសពីយើង***

ពួកគេមានអារម្មណ៍ថាពួកគេមិនចូលចំណោម។ ប្រហែលជាពួកគេខុសពីគេ ពួកគេមើលឃើញថាខ្លួនឯងភ្លាត់ចេញពីហ្វូង។ ពួកគេអាចនឹងមើល ប្រព្រឹត្ត គិត និងនិយាយខុសពីមនុស្សដែលនៅជុំវិញពួកគេ ហើយដែលពេលខ្លះបណ្ដាលឱ្យពួកគេគិតស្មានថាពួកគេមិនចុះសម្រុងនឹងគេ។ ពួកគេសន្និដ្ឋានថាពួកគេមិនសំខាន់។

ភ្ជាប់ទៅនឹងការយល់ច្រឡំនេះ គឺជាការជឿជាក់ដែលខុសឆ្គងដែលថា សមាជិកនៃសាសនាចក្រគួរតែមើលទៅដូចគ្នា និយាយដូចគ្នា និងស្រដៀងគ្នានោះ។ ព្រះអម្ចាស់មិនបង្កើតមនុស្សនៅលើផែនដី ឱ្យមានទេពកោសល្យខាងតន្ត្រីញាប់ញ័រ ដើម្បីគ្រាន់តែឱ្យតម្លៃទៅលើសម្លេងដ៏គ្រលួចនៃពិភពលោកនេះទេ។ គ្រប់ឧបករណ៍ទាំងអស់គឺមានតម្លៃ ហើយកាន់តែបន្ថែមសម្រស់លើភាពដ៏ស្មុគ្រស្មាញនៃសម្លេងមហោរី។ កូនចៅរបស់ព្រះវរបិតាគ្រប់រូបគឺមានភាពខុសគ្នាទៅតាមក៏រិត ហើយគ្រប់គ្នាមានសម្លេងពិរោះរៀងខ្លួន ដែលបន្ថែមអត្ថន័យ និងភាពរស់រវើកទាំងមូល។

ការបង្កើតបែបផែនខុសៗគ្នានេះឯង គឺជាសក្ខីបទពីរបៀបដែលព្រះអម្ចាស់ឱ្យតម្លៃដល់កូនចៅរបស់ទ្រង់។ ទ្រង់មិនគិតថានរណាម្នាក់ខ្ពស់ជាងនរណាម្នាក់ឡើយ ប៉ុន្តែទ្រង់ "អញ្ជើញពួកគេទាំងអស់គ្នា ឱ្យមករកទ្រង់ ហើយទទួលទាននូវសេចក្ដីសប្បុរសរបស់ទ្រង់ ហើយទ្រង់ពុំបដិសេធអ្នកណាម្នាក់ដែលមករកទ្រង់ឡើយ គឺទាំងខ្មៅនិងស ទាំងបាវគេនិងសេរី ទាំងប្រុសទាំងស្រី...ក៏ដូចគ្នានៅចំពោះព្រះដែរ"។3

ខ្ញុំនៅចាំកាលពីខ្ញុំនៅក្មេង មានក្មេងប្រុសធំម្នាក់ដែលពិការទាំងរូបកាយ និងសតិអារម្មណ៍។ គាត់មានការពិបាកក្នុងការនិយាយ និងការដើរ។ ក្មេងប្រុសផ្សេងៗតែងតែចំអកដល់គាត់។ ពួកគេចំអន់ និងឡកឡឺយពេលខ្លះ រហូតដល់គាត់យំ។

ខ្ញុំនៅតែឮសម្លេងគាត់ ដែលបាននិយាយថាៈ "អ្នកមិនដូចខ្ញុំទេ"។ ហើយពួកគេនៅតែចំអកដល់គាត់ រុញគាត់ និងនិយាយកំប្លុកកំប្លែងពីគាត់។

មានថ្ងៃមួយ ខ្ញុំមិនអាចទ្រាំបានទៀតឡើយ។ ទោះបីខ្ញុំជាក្មេងប្រុសដែលមានអាយុទើបតែប្រាំពីរឆ្នាំក្តី ព្រះអម្ចាស់បានផ្តល់សេចក្តីក្លាហានឱ្យខ្ញុំក្រោកឈរនៅចំពោះមុខមិត្តភក្តិរបស់ខ្ញុំ។

ខ្ញុំបាននិយាយទៅកាន់ពួកគេថាៈ "កុំប៉ះគាត់។ កុំចំអកដល់គាត់។ ចូរមានចិត្តល្អ។ គាត់គឺជាកូនរបស់ព្រះ!"

មិត្តភក្តិរបស់ខ្ញុំបានឈានជើងថយក្រោយ ហើយដើរចេញទៅ។

ខ្ញុំងឿយឆ្ងល់ណាស់ តើពេលនោះភាពក្លាហានរបស់ខ្ញុំ និងធ្វើឱ្យអន្តរាយដល់មិត្តភាពរបស់ខ្ញុំជាមួយនឹងពួកគេដែរឬទេ។ ប៉ុន្តែរឿងផ្ទុយបានកើតឡើង។ ចាប់តាំងពីថ្ងៃនោះមក មិត្តរបស់ខ្ញុំ និងខ្ញុំកាន់តែជិតស្និត។ ពួកគេបង្ហាញនូវកំណើននៃសេចក្តីករុណាសំរាប់ក្មេងប្រុសនោះ។ ពួកគេប្រែក្លាយជាមនុស្សជាតិកាន់តែល្អ។ តាមការយល់ដឹងរបស់ខ្ញុំពួកគេមិនដែលចំអកដល់គាត់ទៀតទេ។

បងប្អូនប្រុសស្រីទាំងឡាយ បើសិនជាយើងគ្រាន់តែមានចិត្តករុណាចំពោះអស់អ្នកដែលខុសពីយើង នោះយើងនឹងអាចដោះស្រាយបញ្ហា និងទុក្ខសោកបានជាច្រើននៅក្នុងពិភពលោកយើងសព្វថ្ងៃនេះ។ ហើយវាប្រាកដជាធ្វើឱ្យគ្រួសារ និងសាសនាចក្ររបស់យើងកាន់តែបរិសុទ្ធ និងជាស្ថានសួគ៌ា។

## *មនុស្សមួយចំនួនបានវង្វេងផ្លូវពីព្រោះតែពួកគេទន់ខ្សោយ*

វាងាយស្រួលណាស់ក្នុងការមានអារម្មណ៍អន់ចិត្ត។ ដោយសារសម្ពាធ និងតម្រូវការលើពេលវេលារបស់យើង និងភាពស្មុគ្រស្មាញដែលយើងប្រឈមមុខរាល់ថ្ងៃ ដែលវាធ្វើឱ្យយើងអស់កម្លាំងបន្តិចបន្តួច។ មនុស្សជាច្រើនមានអារម្មណ៍បាក់ទឹកចិត្ត ពីព្រោះពួកគេមិនទាន់បានសម្រេចសក្តានុពលរបស់ពួកគេ។ អ្នកខ្លះមានអារម្មណ៍ថា ទន់ខ្សោយណាស់ក្នុងការបរិច្ចាគ។ ដូច្នេះហើយនៅពេលដែលហ្វូងមនុស្សរំកិលឆ្ពោះទៅមុខបន្តិចម្តង១--- ស្ទើរតែមិនអាចឃើញថា--- មានមនុស្សមួយចំនួនបានធ្លាក់ចុះនៅខាងក្រោយ។

មនុស្សគ្រប់រូបមានអារម្មណ៍នឿយហត់ និងទន់ខ្សោយនៅក្នុងពេលមួយ។ ខ្ញុំមានអារម្មណ៍ថា កាន់តែនឿយហត់ជាងពេលដែលខ្ញុំនៅក្មេង។ លោកយ៉ូសែប ស៊្មីធ លោកព្រិកហ្គាំ យ៉ាំង និងសូម្បីតែព្រះយេស៊ូវគ្រីស្ទ ដឹងពីអត្ថន័យនៃការនឿយហត់នោះ។ ខ្ញុំមិនមានបំណងវាយតម្លៃលើទម្ងន់ ដែលសមាជិកនៃសាសនាចក្រលីនៅលើស្មារ ឬបង្រួមឧបសគ្គដែលពួកគេប្រឈមមុខទាំងផ្នែកសតិអារម្មណ៍ និងវិញ្ញាណរបស់ពួកគេនោះទេ។ រឿងទាំងនេះអាចធ្ងន់ធ្ងរ ហើយពិបាកនៅក្នុងការរំកពន្ធ។

ទោះជាយ៉ាងណាក្តី ខ្ញុំមានទីបន្ទាល់អំពី ព្រះចេស្តាឡើងវិញជាថ្មីនៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ។ ព្យាការីអេសាយ បានប្រកាសថាព្រះអម្ចាស់ "ទ្រង់រមែងចំរើនកម្លាំង ដល់អ្នកដែលល្វើយ ហើយចំណែកអ្នកដែលគ្មានកម្លាំងសោះនោះទ្រង់ ក៏ប្រទានឱ្យ"។4 នៅពេលដែលខ្ញុំអស់កម្លាំង ខ្ញុំនៅចងចាំពាក្យសំដីរបស់ព្យាការីយ៉ូសែប ស៊្មីធ "តើយើងនឹងមិនទៅមុខដោយសារចលនាដ៏ធំមហិមានេះឬ?

"ចូរទៅមុខហើយកុំថយក្រោយឡើយ។ បងប្អូនអើយ ចូរមានចិត្តក្លាហានចុះ ហើយចូរទៅ ចូរទៅរកជ័យជំនះ! ចូរឱ្យចិត្តអ្នកបានអរសប្បាយ ហើយរីករាយជាអតិបរិមាចុះ។ ចូរឱ្យផែនដីទំលាយសម្លេងចេញមក "...ចូរឱ្យពួកអ្នកស្តាប់

បន្លឺសម្លេងច្រៀង...។ ចូរឱ្យព្រៃប្រឹក្សា និងអស់ទាំងឈើ នៅពេញវាល សរសើរដំកើងដល់ព្រះអម្ចាស់...ហើយចូរឱ្យអស់ទាំងកូនព្រះអរសាទរចុះ!"5

ចំពោះអស់អ្នកដែលជាសមាជិកនៃសាសនាចក្រ ដែលស្ទាក់ស្ទើរពីព្រោះតែអារម្មណ៍មិនពេញលេញ ខ្ញុំសូមអង្វរអ្នកឱ្យឈានទៅមុខ ចូរដាក់ស្មាររបស់អ្នកនៅលើនឹម ហើយរុញទៅមុខ។ ទោះបីជាអ្នកមានអារម្មណ៍ថា កម្លាំងរបស់អ្នកបានបន្ថែមតែបន្តិចបន្តួចក្តី សាសនាចក្រត្រូវការអ្នក។ ព្រះអម្ចាស់ត្រូវការអ្នក។ ចូរចាំថា ព្រះអម្ចាស់តែតែងជ្រើសរើសយកមនុស្សកំសោយនៃពិភពលោក ដើម្បីសម្រេចគោលបំណងរបស់ទ្រង់។6

ចំពោះអស់អ្នកដែលទន់ខ្សោយ ចូរឱ្យបន្ទូលលើកទឹកចិត្តរបស់ព្រះអម្ចាស់ លួងលោមអ្នក " អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សំរាក"។7 ចូរយើងពឹងផ្អែកលើការសន្យានោះ។ អំណាចរបស់ព្រះអាចបញ្ចូលថាមពល និងកំលាំងដល់វិញ្ញាណ និងរូបកាយរបស់យើង។ ខ្ញុំសូមជំរុញអ្នកឱ្យស្វែងរកពរជ័យពីព្រះអម្ចាស់។

ចូរចូលទៅជិតទ្រង់ ហើយទ្រង់នឹងចូលទៅជិតអ្នក ព្រោះទ្រង់បានសន្យាថា: " តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំលាំងចំរើនជានិច្ច ហើយគេនឹងហើរឡើងទៅលើដោយស្លាបឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ"។8

ពេលយើងបង្ហាញការព្រួយបារម្ភដល់អស់អ្នកដែលទន់ល្វើយនោះយើង " ជួយអ្នកដែលទន់ខ្សោយ ចូរលើកដៃដែលរោយ ហើយចូរចំរើនកម្លាំងដល់ក្បាលជង្គង់ដែលរញ៉េរផង"។9 អ្នកដឹកនាំសាសនាចក្រ ដែលយកចិត្តទុកដាក់គឺគិតពីដែនកំណត់របស់បុគ្គលម្នាក់ៗ ប៉ុន្តែប្រើប្រាស់សមាជិកទាំងឡាយ ដើម្បីពង្រឹងកម្លាំង និងសមត្ថភាពរបស់សមាជិក។ អ្នកដឹកនាំបង្រៀន ហើយជួយគាំទ្រ ប៉ុន្តែមិនត្រូវដាក់សម្ពាធ ឬធ្វើការច្រើនហួសកម្លាំងដែលមាននោះទេ។10

ចូរចាំថា : នៅពេលខ្លះអ្នកដែលចាប់ផ្តើមយឺតជាងគេបំផុត នៅក្រោយមកនឹងទៅលឿនជាងគេបំផុត។

### *អ្នកខ្លះវង្វេងផ្លូវពីព្រោះតែពួកគេបានដើរខុស*

យើងទាំងអស់គ្មានមានកំហុស លើកលែងតែព្រះអម្ចាស់ប៉ុណ្ណោះ។ សំណួរនោះគឺថាមិនមែន តើយើងជំពប់ជើងហើយដួលនោះទេ ប៉ុន្តែតើយើងឆ្លើយតបដោយរបៀបណា? មនុស្សមួយចំនួនបន្ទាប់ពីធ្វើខុសហើយបានវង្វេងចេញពីហ្វូង។

នេះជារឿងគួរឱ្យសោកស្តាយណាស់។ តើអ្នកដឹងទេថាសាសនាចក្រគឺជាកន្លែងសំរាប់មនុស្សមិនល្អឥតខ្ចោះប្រមូលផ្តុំគ្នា--- សូម្បីតែជីវិតរមែងស្លាប់នេះទន់ខ្សោយក្តី--- ហើយប្រែក្លាយកាន់តែប្រសើរឡើង? ជារៀងរាល់ថ្ងៃអាទិត្យសមាជិកនៅក្នុងគ្រប់សាលាប្រជុំទូទាំងពិភពលោក យើងឃើញថាបុរសស្ត្រី និងកុមារទាំងឡាយ ក្នុងជីវិតរមែងស្លាប់ដែលមិនល្អឥតខ្ចោះត្រូវបានបំភាន់ បានមកជួបជុំគ្នាក្នុងភាពជាបងប្អូនប្រុស ហើយខិតខំដោយក្តីមេត្តាដើម្បីប្រែក្លាយជាមនុស្សកាន់តែប្រសើរឡើង ដើម្បីរៀនផ្អែកខាងវិញ្ញាណ ហើយផ្តល់នូវការលើកទឹកចិត្ត និងការគាំទ្រដល់គ្នាទៅវិញទៅមក។ ខ្ញុំមិនដែលដឹងថា មានសញ្ញានៅលើទ្វារមួយណា នៃសាលាប្រជុំរបស់យើងដែលសរសេរ "បំរាមលើច្រកចូលថា: មានតែមនុស្សឥតខ្ចោះប៉ុណ្ណោះ" ឡើយ។

ពីព្រោះតែភាពមិនល្អឥតខ្ចោះរបស់យើង យើងត្រូវការសាសនាចក្ររបស់ព្រះអម្ចាស់។ នៅទីនោះហើយដែលគោលលទ្ធិទ្រង់ជាអ្នកប្រោសលោះយើងត្រូវបានបង្រៀន ហើយពិធីការសង្គ្រោះរបស់ទ្រង់ត្រូវបានធ្វើឡើយ។ សាសនាចក្របានលើកទឹកចិត្ត និងជំរុញយើងឱ្យប្រែក្លាយជាមនុស្សកាន់តែប្រសើរឡើង និងកាន់តែសប្បាយជាងមុន។ វាក៏ជាកន្លែងដែលយើងបាត់ជីវិតខ្លួនឯងដើម្បីបំរើអ្នកដទៃផងដែរ។

ព្រះអម្ចាស់ជ្រាបថាយើងធ្វើខុស។ នេះហើយជាមូលហេតុដែលទ្រង់រងទុក្ខដើម្បីអំពើបាបរបស់យើង។ ទ្រង់ចង់ឱ្យយើងព្យាយាមម្តងហើយម្តងទៀត ហើយធ្វើឱ្យបានប្រសើរជាងមុន។ មានសេចក្តីអំណរនៅលើមុខពួកទេវតានៃព្រះយេហូវ៉ានោះដែរ ដោយសារមនុស្សបាបតែមួយនាក់ ដែលប្រែចិត្តវិញ។

ចំពោះអស់អ្នកដែលវង្វេងពីព្រោះតែអ្នកអន់ចិត្ត តើអ្នកនឹងបោះបង់ការឈឺចាប់ និងកំហឹងរបស់អ្នកចោលមួយឡែកបានទេ? តើអ្នកអាចបំពេញចិត្តរបស់អ្នកដោយសេចក្តីស្រឡាញ់បានទេ? មានកន្លែងមួយសំរាប់អ្នកនៅទីនេះ។ ចូលមក ហើយចូលរួមនៅក្នុងហ្វូង ឧទ្ទិសសមត្ថភាព ទេពកោសល្យ និងជំនាញទាំងឡាយរបស់អ្នក។ អ្នកនឹងកាន់តែប្រសើរឡើង ហើយអ្នកដទៃនឹងទទួលបានពរជ័យដោយសារតែគំរូរបស់អ្នក។

ចំពោះអស់អ្នកដែលវង្វេងពីព្រោះតែចម្ងល់នៃគោលលទ្ធិ យើងមិនអាចសុំការអភ័យទោសចំពោះសេចក្តីពិតបានទេ។ យើងមិនអាចបដិសេធគោលលទ្ធិដែលផ្តល់មកឱ្យយើងដោយព្រះអម្ចាស់ទ្រង់ផ្ទាល់បានទេ។ ចំពោះគោលលទ្ធិនេះយើងមិនអាចកែសម្រួលបានឡើយ។

ខ្ញុំយល់ថាមនុស្សមួយចំនួនមិនយល់ស្របជាមួយនឹងគោលលទ្ធិនេះ។ ពួកគេថែមទាំងទៅកាន់តែហួស រហូតដល់គិតថាឆ្កួតលីលា។ ប៉ុន្តែខ្ញុំសូមរំលឹកឡើងវិញនូវពាក្យសំដីរបស់សាវក ប៉ុល ដែលបាននិយាយថា នៅពេលខ្លះរឿងខាងវិញ្ញាណអាចលេចឡើងហាក់បីដូចជាឆ្កួតលីលាចំពោះមនុស្សលោក។ ប៉ុន្តែទោះជាយ៉ាងណា " ត្បិតសេចក្តីល្ងង់ល្ងើរបស់ព្រះ នោះមានប្រាជ្ញាលើសជាងមនុស្ស"។11

នៅក្នុងសេចក្តីពិត កិច្ចការរបស់ព្រះវិញ្ញាណគឺបានបើកសម្តែងដោយព្រះវិញ្ញាណ។ "ប៉ុន្តែមនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងវិញ្ញាណទេនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ត្បិតត្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ"។12

យើងសូមថ្លែងទីបន្ទាល់ថា ដំណឹងល្អរបស់ព្រះយេស៊ូវ គ្រីស្ទ គឺមាននៅលើផែនដីយើងសព្វថ្ងៃនេះ។ ទ្រង់បានបង្រៀនពីគោលលទ្ធិរបស់ព្រះវរបិតាទ្រង់ថា: "បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ"។13

ខ្ញុំដឹងថាយើងម្នាក់ៗទាំងទ្រកង្វល់សំរាប់មនុស្សជាទីស្រឡាញ់។ ចូរផ្តល់ការលើកទឹកចិត្ត ការបំរើ និងការគាំទ្រដល់ពួកគេ។ ចូរស្រឡាញ់ពួកគេ។ ចូរចិត្តល្អចំពោះពួកគេ។ នៅក្នុងករណីខ្លះ ពួកគេនឹងត្រឡប់មកវិញ។ អ្នកខ្លះទៀតប្រហែលជាមិនត្រឡប់មកវិញទេ។ ប៉ុន្តែនៅក្នុងគ្រប់ករណីទាំងអស់ ចូរយើងមានភាពសក្តិសម ចំពោះព្រះនាមដល់យើងលើកដាក់លើខ្លួនគឺព្រះយេស៊ូវគ្រីស្ទ។

ចំពោះអស់អ្នកដែលរស់នៅលើផែនដីដ៏ស្រស់ស្អាតនេះ ខ្ញុំសូមបន្លឺសម្លេងរបស់ខ្ញុំ ហើយថ្លែងទីបន្ទាល់ដ៏មុតមាំថា ព្រះទ្រង់មានព្រះជន្ម ហើយថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះ និងជាស្តេចរបស់យើង! ទ្រង់បានស្តារសេចក្តីពិត និងដំណឹងល្អរបស់ទ្រង់ឡើងវិញតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ។ ទ្រង់បានមានព្រះបន្ទូលទៅកាន់ព្យាការី

និងសាវករបស់ទ្រង់ ។ ប្រធានថូម៉ាស អេស ម៉នសុន គឺបានតែងតាំងពីព្រះអម្ចាស់ ហើយលោកដឹកនាំសាសនាចក្រ របស់ទ្រង់សព្វថ្ងៃនេះ ខ្ញុំសូមថ្លែងទីបន្ទាល់នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ម៉ាថាយ 18:11 ។

2. លូកា 15:4 ។

3. នីហ្វៃទី 2 26:33 ។

4. អេសាយ 40:29 ។

5.គ. និង ស. 128:22-- 23 ។

6. គ. និង ស. 1:19 ។

7. ម៉ាថាយ 11:28 ។

8. អេសាយ 40:31 ។

9. គ. និង ស. 81:5 ។

10. គ. និង ស. 10:4 ។

11. កូរិនថូសទី 1 1: 25 សូមមើល ខ. 18 ផងដែរ ។

12. កូរិនថូសទី 1 2:14 ។

13. យ៉ូហាន 7:17 ។